# ប្រាសាទដងវែក (ស្ថាបត្យកម្មចំណាស់ជាងគេនៅសំបូរព្រៃគុក?)

សំបូរព្រៃគុក ឬគេស្គាល់ឈ្មោះដើមថា “ឦសានបុរ” គឺជាអតីតទីតាំងរាជធានីរបស់ខ្មែរកាលពីរវាងចុងស.វ.ទី៦ ដល់ពាក់កណ្តាលស.វ.ទី៧នៃគ្រឹស្តសករាជ ហើយរីកចម្រើនខ្លាំងបំផុតនៅក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧) ដែលអាចមើលឃើញតាមរយៈតឹកតាងសំណង់ស្ថាបត្យកម្ម និងអត្ថបទក្នុងសិលាចារឹក។ អ្វីដែលគួរកត់សម្គាល់ ទិន្នន័យសំណង់ស្ថាបត្យកម្ម ទិន្នន័យផ្នែកបុរាណវិទ្យា (ការកំណាយ) និងសិលាចារឹកមួយចំនួននៅមានកម្រិតស្តួចស្តើងបំផុតដើម្បីអះអាងថា អតីតរាជធានីនេះមានព្រឹត្តិការណ៍នយោបាយតាំងពីមុនរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ ពោល គឺរជ្ជកាលព្រះបាទភវវរ្ម័នទី១ និងព្រះបាទមហេន្ទ្រវរ្ម័ន (ចិត្រាសេន)។ ទោះបីជាយ៉ាងណា មានសិលាចារឹកចំនួនពីរដែលបានរកឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុកដែលមានរៀបរាប់អំពីព្រឹត្តិការណ៍នយោបាយក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី១ និងព្រះបាទមហេន្ទ្រវរ្ម័ន គឺសិលាចារឹកចុះបញ្ជីលេខ K.151 (ប្រាសាទស្រីគ្រប់ល័ក្ខណ តួប៉ម L5) និង K.149 (ប្រាសាទជ្រៃ តួប៉ម N18)។[១] ចំណែកភស្តុតាងផ្នែកបុរាណវិទ្យា តាមរយៈការកំណាយរបស់សាកលវិទ្យាល័យវ៉ាសេដានៅតាមកំពែងទីក្រុងឦសានបុរ និងទីតាំងដទៃទៀត លទ្ធផលឱ្យឃើញថា ស្ថានីយសំបូរព្រៃគុកមានមនុស្សរស់នៅតាំងពីស.វ.ទី៥មកម៉្លេះ។[២] ទិន្នន័យទាំងពីរនេះញុាំងឱ្យអ្នកស្រាវជ្រាវកាន់តែជឿថា មុនចាប់រជ្ជកាលព្រះបាទឦសានវរ្ម័នទី១ នៅអតីតរាជធានីនេះមានព្រះមហាក្សត្រជំនាន់មុនមកតាំងទីរួចទៅហើយ។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញអំពីប្រាសាទមួយដែលអាចមានអាយុកាលចាស់ជាងគេនៅក្នុងក្រុមប្រាសាទសំបូរព្រៃគុក ហើយអាចសាងសង់ឡើងក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី១ (គ.ស.៥៩៨-៦០៦) និងព្រះបាទមហេន្ទ្រវរ្ម័ន (គ.ស.៦០៦-៦១៦) ពោល គឺប្រាសាទដងវែក។

ប្រាសាទដងវែក មានទីតាំងស្ថិតនៅក្នុងក្រុមប្រាសាទសំបូរ ឬក្រុមខាងជើង ដែលស្ថិតនៅឦសានតួប៉មកណ្តាល N1 និងស្ថិតនៅខាងក្រៅកសិន្ធុទឹកនៃក្រុមប្រាសាទសំបូរ។ តួប៉មនេះ សាងសង់ឡើងអំពីឥដ្ឋ មានរាងបួនជ្រុងស្មើ បែរមុខទៅទិសខាងលិច ពោល គឺជាតួប៉មតែមួយគត់នៅក្រុមខាងជើង ដែលបែរមុខទៅទិសខាងលិច (រូបលេខ១-២)។ នៅផ្នែកខាងក្នុង សិល្បកររៀបជាបន្ទប់សក្ការៈមានរាងបួនជ្រុងស្មើ និងច្រកចូលខាងកើតសិល្បកររៀបជារាងសាជីចំហ ដើម្បី

[១] Cœdès 1952: 29; 1943: 5.

[២] Chhum Menghong 2014.

អត្ថបទដោយៈ ម៉ង់ វ៉ាលី

សម្រាលទម្ងន់ឥដ្ឋនៅខាងលើ។ តាមក្បាលជញ្ជាំងស្របនឹងស៊ុមទ្វារខាងលើ គេតម្រៀបជាក្បាច់រាងដូចបន្ទាត់ ខណ្ឌចែកជាមួយផ្នែកខាងលើ ហើយក្រៅពីនេះនៅផ្នែកខាងជើងពាក់កណ្ដាលជញ្ជាំងប្រាសាទ មានសោមសូត្រមួយបង្ហូរទឹកមន្តទៅទិសខាងជើង (រូបលេខ២៥) ដែលទបង្ហូរទឹកនេះហើយដែលអ្នកស្រុកយល់ថាជា "**ដងរែក**" រហូតដល់យកឈ្មោះនេះជាពាក្យហៅសំដៅឈ្មោះប្រាសាទតែម្ដង។

ផ្នែកខាងក្រៅនៃប្រាសាទដងរែក សិល្បកររៀបជញ្ជាំងខាងជើង ខាងត្បូង និងខាងកើតជាក្បាច់សសរផ្ដោប ដោយមិនមានទ្វារបញ្ឆោតដូចប្រាសាទដទៃទៀតឡើយ។ លក្ខណៈបែបនេះ វាមានលក្ខណៈស្រដៀងប្រាសាទផ្សេងៗទៀតក្នុងក្រុមខាងជើងដូចជា តួប៉ម N8, N12, N13 ។ល។ នៅខាងលើក្បាលសសរផ្ដោបជាន់ទី១ គេរៀបឥដ្ឋដូចជាបន្ទះត្រង់ខណ្ឌចែកផ្នែកតួនិងដំបូលដែលលក្ខណៈបែបនេះមិនសូវមាននៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុកឡើយ។ ក្រៅពីនេះ នៅផ្នែកកំពូលគេមានលម្អជាក្បាច់គូឌុដែលមានឆ្លាក់រូបក្បាលមនុស្សឬទេពនៅក្នុងរាងជាក្របកសេះ ដែលជាក្បាច់ដែលនិយមខ្លាំងនៅសំបូរព្រៃគុក និងទទួលឥទ្ធិពលពីសិល្បៈឥណ្ឌា (រូបលេខ២៦-៧)។

ការរៀបចំសំណង់ជាទូទៅនៃប្រាសាទដងរែក មិនមានលក្ខណៈដូចគ្នាទាំងស្រុងជាមួយប្រាសាទណាមួយនៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុកឡើយ ពោល គឺគ្រាន់តែស្រដៀងប្រាសាទមួយចំនួននៅក្នុងខាងជើង (តួប៉ម N8, N12, N13) និងក្រុមកណ្ដាល (តួប៉ម C2 – C4)។ ដោយឡែកប្រសិនបើយើងប្រៀបធៀបជាមួយសំណង់ប្រាសាទនៅតំបន់ថាឡាបរិវ៉ាត់វិញ យើងឃើញការលម្អសសរផ្ដោបនៅតាមជញ្ជាំងខាងក្រៅ និងការលម្អក្បាច់គូឌុ មានលក្ខណៈស្រដៀងប្រាសាទព្រះគោ (រូបលេខ២៨)។ ជាទូទៅបើគេយោងទៅលើសិលាចារឹកជាច្រើនដែលរកឃើញនៅថាឡាបរិវ៉ាត់ និងទិន្នន័យផ្នែកបុរាណវិទ្យា សំណង់ប្រាសាទនៅទីនោះអាចសាងសង់ឡើងចាប់ពីរវាងចុងស.វ.ទី៦ ឬដើមស.វ.ទី៧ ពោល ទំនងរជ្ជកាលព្រះបាទភវវរ្ម័នទី១ និងព្រះបាទមហេន្ទ្រវរ្ម័ន។ ម្ល៉ោះហើយ សំណង់ប្រាសាទដងរែក ទំនងជាសំណង់ប្រាសាទដ៏ចំណាស់ជាងគេនៅតំបន់សំបូរព្រៃគុក ដែលទំនងសាងសង់ឡើងតំណាលប្រាសាទមួយចំនួននៅតំបន់ថាឡាបរិវ៉ាត់ ក្នុងរវាងរជ្ជកាលព្រះបាទភវវរ្ម័នទី១ (គ.ស.៥៩៨-៦០៦) និងព្រះបាទមហេន្ទ្រវរ្ម័ន (គ.ស.៦០៦-៦១៦)៕

## ឯកសារយោង

**Chhum Menghong**

2014, *The study on basic structure and urbanism of khmer ancient city Isanapura*, Tokyo.

**Coedès, George**

1943, "Quelque précisions sur la fin du Fou-Nan" *BEFEO*, Tome 43, Paris.

1952, *Inscription du Cambodge*, Vol IV, Hanoi.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ១៖ ប្រាសាទដងវែក (មើលពីមុខខាងលិច) (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ២៖ ប្រាសាទដងវែក (មើលពីមុខពាយព្យ) (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៣៖ ប្រាសាទដង់វែក (មើលពីមុខអាគ្នេយ៍) (រូបថត៖ ស្រី សមប៊ុនណារ៉ុង)



រូបលេខ៤៖  ប្រាសាទដង់វែក (មើលពីមុខខាងកើត)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៥៖ សោមសូត្រឬទបង្ហូរទឹកនៅខាងក្នុងប្រាសាទដងវែក
(មើលពីមុខខាងលិច) (រូបថត៖ ស្រី សមប៊ុនណារ៉ុង)



រូបលេខ៦-៧៖ ចម្លាក់គូឌុនៅផ្នែកកំពូលប្រាសាទដងវែក (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៨៖ ប្រាសាទព្រះគោ (ថាឡាបរិវ៉ាត់) (មើលពីមុខពាយ័ព្យ)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី